N. 48
31.12.02

# ក

## មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២០-១២- ២០០២ | -ព្រះរាជក្រឹត្យ នស/រកត/១២០២/៣៤៩ ស្ដីពី ការតម្លើងឋានន្តរសក្ដិថ្នាក់ ឧត្តមសេនីយ៍ត្រីជូនចំពោះលោកវរៈសេនីយ៍ឯក **ហ៊ិន យក់លីម** | ៣៥១៣ |
| ២៤-១២-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/១២០២/៣៥០ ស្ដីពី ការផ្ទេរនិងបញ្ចូលក្របខ័ណ្ឌ ឧត្តមសេនីយ៍ត្រី ០៣ រូបពីក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទនៃក្រសួង ការពារជាតិឱ្យមកបំរើ ការងារ នៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ | ៣៥១៤ |
| ២៤-១២-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/១២០២/៣៥១ ស្ដីពីការតែងតាំងឯកឧត្តម **លី អាមឡាក់** ជាអនុរដ្ឋលេខាធិការ នៃទីស្ដីការគណៈរដ្ឋមន្ត្រី ជំនួសឯកឧត្តម **ហេង មូ** | ៣៥១៥ |
| ២៨-១២-២០០២ | -ព្រះរាជក្រឹត្យ នស/រកត/១២០២/៣៥៣ ស្ដីពី ការបង្កើត "**ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**"ហៅកាត់ថា "**គបស**" ដែលជាស្ថាប័នខួរក្បាលខាងផ្នែកគោលនយោបាយ សេដ្ឋកិច្ចសំរាប់ប្រមុខនៃរាជរដ្ឋាភិបាលនៅអមទីស្ដីការគណៈរដ្ឋមន្ត្រី | ៣៥១៦ |


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ២៦-១២-២០០២ | -អនុក្រឹត្យលេខ ១២៧ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា | ៣៥២១ |
| ២៦-១២-២០០២ | -អនុក្រឹត្យលេខ ១២៨ អនក្រ.បក ស្ដីពី ការបង្កើតអង្គភាពគ្រប់គ្រងគំរោង កំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ | ៣៥២៣ |
| ៣០-១២-២០០២ | -អនុក្រឹត្យលេខ ១២៩ អនក្រ.បក ស្ដីពី ការគ្រប់គ្រងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ៣៥២៨ |
| ២៣-១២-២០០២ | -អនុក្រឹត្យលេខ ៥៨៣ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ | ៣៥៣០ |
| ២៣-១២-២០០២ | -អនុក្រឹត្យលេខ ៥៨៤ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ | ៣៥៣៣ |
| ២៣-១២-២០០២ | -អនុក្រឹត្យលេខ ៥៨៥ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី | ៣៥៣៧ |
| ២៤-១២-២០០២ | -អនុក្រឹត្យលេខ ៥៨៦ អនក្រ.តត ស្ដីពី ការជូនមេដាយមាសការងារ | ៣៥៣៩ |
| ២៤-១២-២០០២ | -អនុក្រឹត្យលេខ ៥៨៧ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ | ៣៥៤១ |
| ២៤-១២-២០០២ | -អនុក្រឹត្យលេខ ៥៨៨ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ | ៣៥៤៣ |
| ២៤-១២-២០០២ | -អនុក្រឹត្យលេខ ៥៨៩ អនក្រ.តត ស្ដីពី ការផ្ទេរភារកិច្ច និង តែងតាំងមន្ត្រីរាជការ | ៣៥៤៥ |
| ២៤-១២-២០០២ | -អនុក្រឹត្យលេខ ៥៩០ អនក្រ.តត ស្ដីពី ការតែងតាំងក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនសំភារៈកសិកម្ម | ៣៥៤៦ |

២៤-១២-២០០២ -អនុក្រឹត្យលេខ ៥៩១ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣៥៤៧
២៥-១២-២០០២ -អនុក្រឹត្យលេខ ៥៩២ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៣៥៥០
២៦-១២-២០០២ -អនុក្រឹត្យលេខ ៥៩៣ អនក្រ.តត ស្ដីពី ការតែងតាំងក្រុមប្រឹក្សាភិបាល សំរាប់ដឹកនាំក្រុមហ៊ុន **ហ្វ្រីនត្រេដ** អាណត្តិទី ២ ៣៥៥១
២៧-១២-២០០២ -អនុក្រឹត្យលេខ ៥៩៤ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៣៥៥៣
២៧-១២-២០០២ -អនុក្រឹត្យលេខ ៥៩៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣៥៥៤
២៧-១២-២០០២ -អនុក្រឹត្យលេខ ៥៩៦ អនក្រ.តត ស្ដីពី ការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត ៣៥៥៥
២៧-១២-២០០២ -អនុក្រឹត្យលេខ ៥៩៧ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៣៥៥៦
២៧-១២-២០០២ -អនុក្រឹត្យលេខ ៥៩៨ អនក្រ.តត ស្ដីពី ការបញ្ចប់អាណត្តិបេសកកម្មរបស់មន្ត្រីការទូត ៣៥៥៧
២៧-១២-២០០២ -អនុក្រឹត្យលេខ ៥៩៩ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ៣៥៥៨
៣០-១២-២០០២ -អនុក្រឹត្យលេខ ៦០០ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣៥៥៩
៣០-១២-២០០២ -អនុក្រឹត្យលេខ ៦០១ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣៥៦០
៣០-១២-២០០២ -អនុក្រឹត្យលេខ ៦០២ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣៥៦១
៣០-១២-២០០២ -អនុក្រឹត្យលេខ ៦០៣ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៣៥៦២
៣១-១២-២០០២ -អនុក្រឹត្យលេខ ៦០៤ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៣៥៦៣
៣១-១២-២០០២ -អនុក្រឹត្យលេខ ៦០៥ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៣៥៦៤

## ២_សេចក្ដីសំរេច

២៤-១២-២០០២ -សេចក្ដីសំរេចលេខ ៥៤ សសរ ស្ដីពី ការបង្កើតក្រុមការងារសម្របសម្រួលជាមួយសហគមន៍ អ្នកផ្ដល់ជំនួយ ៣៥៦៥
២៧-១២-២០០២ -សេចក្ដីសំរេចលេខ ៥៥ សសរ ស្ដីពី ការបង្កើតគណៈបញ្ជាការ ការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៣ ហៅកាត់ថា "ការិយាល័យសន្តិសុខថ្នាក់កណ្ដាល" ៣៥៦៧

## III-ការងារបណ្ដាក្រសួង

## ១_ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៣-១២-២០០២ -ប្រកាសលេខ ៨៩៨ សហវ.ប្រក ស្ដីពីការបង្កើតគណៈកម្មការពិនិត្យការដេញថ្លៃ ៣៥៦៩

## ២_ធនាគារជាតិ នៃ កម្ពុជា

២៥-១២-២០០២ -ប្រកាសលេខ ធ ៧.០២-២១៨ ប្រក ស្ដីពី ការដាក់ឱ្យអនុវត្តប្លង់គណនី សំរាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៣៥៧១
២៥-១២-២០០២ -Prakas N° B7.02.218 Pror Kor On Adoption and Implementation of Chart of Accounts For Banking and Financial Institutions ៣៥៧៣

# គ


| | | |
|---|---|---|
| ២៥-១២-២០០២ | -ប្រកាសលេខ ធ៧.០២-២១៩ ប្រក ស្តីពី ការដាក់ឱ្យអនុវត្តប្លង់គណនី សំរាប់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ៣៥៧៥ |
| ២៥-១២-២០០២ | -Prakas N° B7.02.219 Pror Kor On Adoption and Implementation of Chart of Accounts For Micro- Finance Institutions | ៣៥៧៧ |
| ២៥-១២-២០០២ | -ប្រកាសលេខ ធ៧.០២-២២០ ប្រក ស្តីពី ការប្រតិបត្តិការលើមូលប័ត្រ របស់ ធនាគារដែលមានអាជ្ញាប័ណ្ណ នៅក្នុងព្រះរាជាណាចក្រកម្ពុជា | ៣៥៧៩ |
| ២៥-១២-២០០២ | -Prakas N° B7.02.220 Pror Kor On Broker Dealer Operation of Banks Licensed in Cambodia | ៣៥៨២ |


## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ


| | | |
|---|---|---|
| ២០-១២-២០០២ | -ប្រកាសលេខ ២៨២៨ ប្រក ស្តីពី នីតិវិធីនិងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរ ឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ សំរាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត | ៣៥៨៤ |

# ព្រះរាជក្រឹត្យ

នស/រកត/១២០២/៣៤៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនចំពោះលោកវរសេនីយ៍ឯក **ហ៊ិន យក់លីម** អត្តលេខ ០៥០០ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : ២៦១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

ពរស-០៤.១៤.០០៣៧០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០២

# ព្រះរាជក្រឹត្យ

នស/រកត/១២០២/៣៥០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ផ្ទេរ និងបញ្ចូលក្របខ័ណ្ឌឧត្តមសេនីយ៍ត្រី ០៣រូប ពីក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ នៃក្រសួងការពារជាតិ អោយមកបំរើការងារ នៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ក្នុងឋានន្តរសក្តិ និងថ្នាក់ដូចខាងក្រោម :

១- ឯកឧត្តម **ឈឹម ឈន** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣
២- ឯកឧត្តម **ម៉ៅ ទឹម** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤
៣- ឯកឧត្តម **ម៉ៅ តិរុណា** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៤

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ២៦២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

៣រស.០២.១២.០០៣៧១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០២

# ព្រះរាជក្រឹត្យ

នស/រកត/១២០២/៣៥១

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **លី អ៊ាមឡាក់** ជាអនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ជំនួសឯកឧត្តម **ហេង មូ** ដែលបានទទួលតំណែងថ្មី ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល.០៧.១៧.០០៣៣៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ២០០២*

លេខ : ២៧០ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១២០២/៣៧៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១៖**

ត្រូវបានបង្កើត "ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ" ហៅកាត់ថា "**គបស**" ដែលជាស្ថាប័នខួរក្បាលខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចសំរាប់ប្រមុខនៃរាជរដ្ឋាភិបាល នៅអមទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ២
## មុខងារ និង ភារកិច្ច

**មាត្រា ២:**

កបស មានមុខងារ និង ភារកិច្ច មានដូចតទៅ :

-ពិនិត្យ និង រៀបចំឯកសារវិភាគ ស្រាវជ្រាវ និង សុន្ទរកថាសំខាន់ៗ ព្រមទាំងលើកឡើងគំនិតផ្តួចផ្តើម ទាំងឡាយ ដែលមានចរិតជាចក្ខុវិស័យគោលនយោបាយ និង យុទ្ធសាស្ត្រកែទំរង់ និង អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ជូនប្រមុខរាជរដ្ឋាភិបាល ។

-ធ្វើជាសេនាធិការជូនប្រមុខរាជរដ្ឋាភិបាល ក្នុងការតាមដាន និង បូកសរុបការអនុវត្តន៍ការងារកែទំរង់ និង គំនិតផ្តួចផ្តើមនានាក្នុងផ្នែកសេដ្ឋកិច្ច ដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញផ្ទាល់ ។

-ធ្វើជាសេនាធិការជូនប្រមុខរាជរដ្ឋាភិបាល ក្នុងការតាមដាន និង បូកសរុបរបាយការណ៍នានា ដែលពាក់ព័ន្ធនឹងការអនុវត្តន៍ផែនការប្រចាំឆ្នាំ និង កម្មវិធីអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល ព្រមទាំងផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីធានាអោយបាននូវសង្គតិភាព និងភាពរលូននៅក្នុងគោលនយោបាយសេដ្ឋកិច្ចជាតិ ព្រមទាំងដើម្បីតំរង់ទិស និង បង្កើនល្បឿននៃការអនុវត្តន៍ផែនការ និង កម្មវិធីទាំងនោះ ។

-រៀបចំអនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល សំដៅធានាអោយបាននូវគុណភាព និងសង្គតិភាពនៃគោលនយោបាយសេដ្ឋកិច្ចនៅក្នុង និងរវាងវិស័យនានា និងផ្តល់យោបល់ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីដាក់ចេញនូវទិសដៅច្បាស់លាស់ សំរាប់ការអនុវត្តន៍អោយបានរលូននូវគោលនយោបាយ និង យុទ្ធសាស្ត្រនៃផែន ការប្រចាំឆ្នាំ និង កម្មវិធីវិនិយោគសាធារណៈ ។

-ស្នើឡើងនូវវិធានការជាក់ស្តែងនានា ក្នុងទិសដៅកែលំអការគ្រប់គ្រងសេដ្ឋកិច្ច និង ពង្រឹង អភិបាលកិច្ចល្អ ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

-បូកសរុប និង ធ្វើរបាយការណ៍សង្ខេបជូនប្រមុខរាជរដ្ឋាភិបាលជ្រាប អំពីស្ថានការណ៍សេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និង សេដ្ឋកិច្ចអន្តរជាតិ ហើយផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសំរបសំរួលដំណើរការនយោបាយសេដ្ឋកិច្ចជាតិ អោយស្របទៅតាមនិន្នាការវិវត្តន៍នៃ សេដ្ឋកិច្ចតំបន់ និង សេដ្ឋកិច្ចអន្តរជាតិ ។

-រៀបចំអោយមានជំនួបរវាង កបស ជាមួយនាយករដ្ឋមន្ត្រី ដើម្បីទទួលបាននូវការវាយតម្លៃ និង ការណែនាំ នៅក្នុងទិសដៅកែលំអការងាររបស់ កបស ។

## ជំពូកទី ៣
## សមាសភាព និង រចនាសម្ព័ន្ធចាត់តាំងនៃ កបស

**មាត្រា ៣:**

សមាសភាពនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រួមមាន:

-ប្រធាន និង អនុប្រធាន កបស ដែលត្រូវមានសមត្ថភាពខាងផ្នែកចំណេះវិជ្ជា និង នៅក្នុងការបំពេញការងារពិសេសគឺការងារពាក់ព័ន្ធនឹងការវិភាគ និង ការរៀបចំចក្ខុវិស័យ គោលនយោបាយ និង យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

-សមាជិកយ៉ាងតិចប្រាំរូប ដែលត្រូវមានគុណសម្បត្តិ ចំណេះវិជ្ជា និង បទពិសោធន៍ការងារក្នុងវិស័យណាមួយនៃមុខជំនាញសេដ្ឋកិច្ច ហិរញ្ញវត្ថុ នីតិសាស្ត្រ ពាណិជ្ជកម្ម កសិកម្ម ការគ្រប់គ្រង ធនធានធម្មជាតិ បរិស្ថាន ឬ ឧស្សាហកម្ម ។

-សមាជិក កបស នីមួយៗ អាចមានមន្ត្រីជំនួយការផ្នែកស្រាវជ្រាវ និង វិភាគគោលនយោបាយ ចំនួនពីររូប ដែលត្រូវមានសមត្ថភាពខាងផ្នែកចំណេះដឹងយ៉ាងតិចចាប់ពីថ្នាក់បរិញ្ញាប័ត្រឡើង ។

-ប្រធាន កបស មានឋានៈស្មើ រដ្ឋមន្ត្រី ។

-អនុប្រធាន កបស មានឋានៈស្មើ រដ្ឋមន្ត្រី ។

-សមាជិក កបស អាចមានឋានៈស្មើ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ ។

-មន្ត្រីជំនួយការស្រាវជ្រាវ និង វិភាគគោលនយោបាយ អាចមានឋានៈស្មើ អគ្គនាយក ឬ អគ្គ- នាយករង ឬ ប្រធាននាយកដ្ឋាន ។

**មាត្រា ៤:**

-កបស មានប្រធានកិត្តិយសមួយរូប ដែលត្រូវបានជ្រើសរើសឡើងពីក្នុងចំណោមឥស្សរជន ដែល មានគុណសម្បត្តិក្នុងការបំរើប្រទេសជាតិ មានបទពិសោធន៍ខ្ពស់ និង មានការទទួលស្គាល់នៅក្នុងមជ្ឈដ្ឋានជាតិ និង នៅលើឆាកអន្តរជាតិ ។

-ប្រធានកិត្តិយស កបស មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។

**មាត្រា ៥:**

-កបស អាចមានទីប្រឹក្សាកិត្តិយសមួយចំនួនដែលត្រូវបានជ្រើសរើសឡើងពីក្នុងចំណោមឥស្សរជន ជាតិខ្មែរ ឬ បរទេស ដែលមានគុណសម្បត្តិក្នុងការបំរើអោយផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា មានបទពិសោធន៍ ខ្ពស់ និង មានការទទួលស្គាល់នៅក្នុងមជ្ឈដ្ឋានជាតិ និង នៅលើឆាក អន្តរជាតិ ។

-កបស អាចមានអ្នកជំនាញការជាតិ និង អន្តរជាតិមួយចំនួន ដែលមានសមត្ថភាពជំនាញ និង បទពិសោធន៍ ខ្ពស់ ដើម្បីជួយបំរើការងារជាទីប្រឹក្សាបច្ចេកទេស ។

**មាត្រា ៦:**

-កបស មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ សំរាប់គាំទ្រ និង ដំណើរការការងាររបស់ខ្លួន ។

-អគ្គលេខាធិការដ្ឋាន កបស ជាស្ថាប័នប្រតិបត្តិ ដែលដឹកនាំ និង គ្រប់គ្រងដោយអគ្គលេខាធិការ មួយរូប មានឋានៈស្មើរដ្ឋលេខាធិការ និង អគ្គលេខាធិការរងពីររូបជាជំនួយការ ដែលអាចមាន ឋានៈស្មើ អនុរដ្ឋលេខាធិការ ឬ អគ្គនាយក ។

-មន្ត្រីបំរើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន កបស គឺជាមន្ត្រីរាជការ នៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។ ក្នុងករណីចាំបាច់ កបស អាចមានអ្នកជំនាញ ឬ បុគ្គលិកជាប់កិច្ចសន្យា ដើម្បី បំពេញការងារនៅក្នុងអគ្គលេខាធិការដ្ឋានរបស់ខ្លួន ។

-ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន កបស ត្រូវកំណត់ដោយអនុក្រឹត្យមួយ ដោយឡែក ។

## ជំពូកទី ៤
## កិច្ចដំណើរការនៃ កបស

**មាត្រា ៧:**

កបស បើកការប្រជុំរបស់ខ្លួន ទៅតាមតំរូវការចាំបាច់ តាមការអញ្ជើញរបស់ប្រធាន ឬ តាមសេចក្តីបង្គាប់របស់សម្តេចនាយករដ្ឋមន្ត្រី ។

**មាត្រា ៨:**

-ដើម្បីអាចបំពេញការងាររបស់ខ្លួន ដូចមានចែងក្នុងមាត្រា ២ ខាងលើ ជូនប្រមុខរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ កបស ត្រូវមានតំណាងចូលរួមតាមដាន និង ផ្តល់យោបល់ នៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី និងអង្គប្រជុំអន្តរក្រសួងផ្សេងៗ ដែលរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី និង ដោយក្រសួង-ស្ថាប័ននានា នៅក្នុងទិសដៅធានានូវសង្គតិភាព និង ភាពរលូននៅក្នុងការរៀបចំគោលនយោបាយយុទ្ធសាស្ត្រ និង វិធានការកែទំរង់នានារបស់រាជរដ្ឋាភិបាល ។

-គ្រប់ក្រសួង និង ស្ថាប័នដែលមានការពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល មានភារកិច្ចផ្តល់ ឯកសារពត៌មាន និងកិច្ចសហការចាំបាច់នានាជូនដល់ កបស ។

-កបស មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់នៃក្រសួង-ស្ថាប័ននានានៃរាជរដ្ឋាភិបាល ឬ ឥស្សរជនដែលមានបទពិសោធន៍ និងសមត្ថភាពខ្ពស់ ដើម្បីមកចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួន ។

**មាត្រា ៩:**

កបស មានសិទ្ធិប្រើប្រាស់ត្រារបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីក្នុងកិច្ចដំណើរការការងាររបស់ខ្លួន ។

## ជំពូកទី ៥
## ប្រភពធនធាន

**មាត្រា ១០:**

-កបស មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌ ថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

-កបស មានសិទ្ធិទទួល និង គ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពជំនួយបរទេស និង ពីប្រភព ផ្សេងទៀត សំរាប់ចំណាយលើសេវារដ្ឋបាល និង សំរាប់បំរើសេចក្តីត្រូវការក្នុងការផ្គត់ផ្គង់សំភារៈ បរិក្ខារ និង ការឧបត្ថម្ភផ្សេងៗតាមការចាំបាច់ ក្នុងគោលដៅធានានូវប្រសិទ្ធភាពក្នុងការបំពេញ មុខងារ និង ភារកិច្ចរបស់ខ្លួន ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១១:**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១២:**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តនូវព្រះរាជក្រឹត្យនេះ អោយមានប្រសិទ្ធភាព ។

**មាត្រា ១៣:**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហត្ថលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី២៨ខែ ធ្នូ ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

៣ស-០២-១២-០០៣៧៤

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ ព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ២៦៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខី តាន់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ១២៣ អនុក្រ.បក

# អនុក្រឹត្យ
# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក,ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៥៧០ លានរៀល ( ប្រាំរយចិតសិបលានរៀលគត់ ) ពីជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) ចំនួន ៤៨ លានរៀល ( សែសិបប្រាំបីលានរៀលគត់ ) និង ពីជំពូក ៣២ ( អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ វិភាគទានអោយអង្គការអន្តរជាតិនានា ) ចំនួន ៥២២ លានរៀល ( ប្រាំរយម្ភៃពីរលានរៀលគត់ ) មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការ ជួសជុលតូច ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់សោហ៊ុយទទួលភ្ញៀវបរទេស ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១២៩ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតអង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៦០២ / ១៥៨ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០២ ស្ដីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្ដីពីការបង្កើតអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងបព័ន្ធ យុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្ដីពីភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-យោងតាមសំណើរបស់សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

**សំរេច**

**មាត្រា ១.-**

ត្រូវបានបង្កើតអង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីជួយអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ (អ.ស.អ) ក្នុងការបំពេញតួនាទី ជាសេនាធិការ នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (ក.ក.ច.យ) ។

81

**មាត្រា ២.-**

អង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានភារកិច្ច ដូចតទៅ :

-គ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅ និងកិច្ចការហិរញ្ញវត្ថុ របស់គំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-ទំនាក់ទំនងសំរបសំរួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំទស្សនាទាន គំរោង ផែនការ និងកម្មវិធីការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដាក់ជូនអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ ពិនិត្យពិភាក្សា ដាក់ជូនក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ពិនិត្យ និងសំរេច

-សំរបសំរួល និងធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិ ជំរុញនិងពង្រឹងការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-តាមដាន និងធ្វើរបាយការណ៍ បូកសរុបលទ្ធផល នៃការអនុវត្តគំរោងកម្មវិធីកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅតាមបណ្តាក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដាក់ជូន អ.ស.អ ពិនិត្យលើកយោបល់ជូន ក.ក.ច.យ

-រ៉ាប់រងការងារឯកសារទាំងអស់របស់ ក.ក.ច.យ និងរបស់ អ.ស.អព្រមទាំងឯកសារដទៃទៀតពាក់ព័ន្ធដល់ការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-រៀបចំការប្រជុំនានារបស់ ក.ក.ច.យ និងរបស់ អ.ស.អព្រមទាំងការប្រជុំផ្សេងៗទៀតទាក់ទងដល់ការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បំពេញការងារផ្សេងៗទៀត ដែល អ.ស.អ និង ក.ក.ច.យប្រគល់ជូន ។

**មាត្រា ៣.-**

អង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដឹកនាំដោយនាយកអង្គភាពគ្រប់គ្រងគំរោង ០១រូប ថ្នាក់ស្មើ អគ្គនាយក និងមាននាយករងជាជំនួយការ ។

អង្គភាពគំរោង មានរចនាសម្ព័ន្ធ ដូចតទៅ :

១-ក្រុមគំរោងរដ្ឋបាល និងហិរញ្ញវត្ថុ

២-ក្រុមគំរោងកំណែទំរង់ច្បាប់

៣-ក្រុមគំរោងកំណែទំរង់ប្រព័ន្ធយុត្តិធម៌

៤-ក្រុមគំរោងការពារសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម

៥-ក្រុមគំរោងបណ្ណសារ និងពត៌មានវិទ្យា ។

អង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ អាចពង្រីករចនាសម្ព័ន្ធរបស់ខ្លួនបានតាមការចាំបាច់ ។

**មាត្រា ៤.-**

ក្រុមគំរោងរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ច :

-ជួយ អ.ស.អ ក្នុងការងារគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់គំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ

-គ្រប់គ្រង និងចរាចរ លិខិត ឯកសាររដ្ឋបាលផ្សេងៗរបស់ អ.ស.អ និង ក.ក.ច.យ

-ធានាប្រសិទ្ធិភាព និងសុវត្ថិភាពរដ្ឋបាលរបស់អង្គភាពគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ

-បូកសរុប និងធ្វើរបាយការណ៍ ស្តីពីការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ

-គ្រប់គ្រងផ្នែករដ្ឋបាលនូវមន្ត្រីបុគ្គលិករបស់អង្គភាពគ្រប់គ្រងគំរោង

-បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ អ.ស.អ និងក.ក.ច.យ ។

**មាត្រា ៥.-**

ក្រុមគំរោងកំណែទំរង់ច្បាប់ មានភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវ លើកគំរោង កែលំអ ពង្រឹងសមត្ថភាពកសាងច្បាប់នៅតាមក្រសួង ស្ថាប័នរដ្ឋ

-សិក្សាស្រាវជ្រាវ រៀបចំនីតិវិធី នៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋាននានា

-សិក្សាស្រាវជ្រាវរៀបចំសន្ទានុក្រម វចនានុក្រម វាក្យសព្ទ ពាក្យពេចន៍ និង ប្រជុំពាក្យផ្នែកច្បាប់

-លើកគំរោង និងធ្វើការអប់រំផ្សព្វផ្សាយច្បាប់

-បំពេញភារកិច្ចផ្សេងៗ តាមការប្រគល់ជូនរបស់ អ.ស.អ និង ក.ក.ច.យ ។

**មាត្រា ៦.-**

ក្រុមគំរោងកំណែទំរង់ប្រព័ន្ធយុត្តិធមិ មានភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវ លើកគំរោង កែលំអ ពង្រឹងសេវាយុត្តិធមិអោយមានឯករាជ្យភាព តម្លាភាព ជំនឿទុកចិត្ត និងការទទួលខុសត្រូវខ្ពស់

-សិក្សាស្រាវជ្រាវ រៀបចំកម្មវិធីបង្កើនគុណភាពសេវាប្រព័ន្ធយុត្តិធមិ ធ្វើអោយប្រសើរឡើងនូវការផ្តល់ជំនួយសេវាផ្នែកច្បាប់ ការអប់រំ និងបណ្តុះ បណ្តាលមេធាវី

-សិក្សាស្រាវជ្រាវ រៀបចំកម្មវិធីធ្វើអោយប្រសើរឡើងនូវប្រព័ន្ធសំរាប់អនុវត្តសេចក្តីសំរេចរបស់តុលាការ និងជំរុញអោយមានមូលដ្ឋានទិន្នន័យ នៃសេចក្តីរបស់តុលាការពីមុនៗមក

-បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ អ.ស.អ និងក.ក.ច.យ ។

**មាត្រា ៧.-**

ក្រុមគំរោងការពារសិទ្ធិមនុស្ស និងវិជ្ជាត្តកម្ម មានភារកិច្ចដូចតទៅ:

-សិក្សាស្រាវជ្រាវ និងរៀបចំកម្មវិធីបង្កើតយន្តការ និងពង្រឹងការការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋអោយកាន់តែប្រសើរឡើង

-សិក្សារៀបចំនីតិវិធី និងយន្តការដោះស្រាយជម្លោះជំនួសការកាត់ក្តីសាមញ្ញ

-បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ អ.ស.អ និងក.ក.ច.យ ។

**មាត្រា ៨.-**

ក្រុមគំរោងឯកសារ និងពត៌មានវិទ្យា មានភារកិច្ចដូចតទៅ :

-ប្រមូល ចងក្រង ទុកដាក់ពត៌មាន និងឯកសារនានាពាក់ព័ន្ធដល់ការងារកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-រៀបចំអត្ថបទ និងបោះពុម្ពផ្សាយ ព្រឹត្តិប័ត្ររបស់ អ.ស.អ និង ក.ក.ច.យ

-ផ្តល់សេវាពត៌មានវិទ្យាដល់គ្រប់ក្រុមគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិ ធម៌

-កសាងមូលដ្ឋានទិន្នន័យច្បាប់ និងប្រមូលទិន្នន័យច្បាប់ទៅក្នុងប្រព័ន្ធពត៌មាន វិទ្យា

-បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ អ.ស.អ និងក.ក.ច.យ ។

**មាត្រា ៩.-**

ក្រុមគំរោងនីមួយៗ ដឹកនាំដោយប្រធានក្រុមគំរោង ០១រូប ថ្នាក់ស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានជាជំនួយការ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គំរោងនីមួយៗ ត្រូវកំណត់ដោយសេចក្តីសំរេច របស់ប្រធាន អ.ស.អ ។

**មាត្រា ១០.-**

មន្ត្រីដែលបំរើការនៅក្នុងអង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាមន្ត្រីនៃមុខងារសាធារណៈ និងអាចជ្រើសរើសជាប់កិច្ចសន្យាតាមការចាំបាច់ ព្រមទាំងអាចទទួលនូវប្រាក់ឧត្តម្ភផ្សេងៗ ដែលបានផ្តល់ពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិនានា ។

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ឱក មន្ទី** **សុខ អាន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១២៩ អនក្រ.បក**

## អនុក្រឹត្យ

**ស្តីពី**

## ការគ្រប់គ្រងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី.
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**<u>ស ំ រេ ច</u>**

**មាត្រា១.-**

ត្រូវបានដំឡើងថ្នាក់ស្មើមន្ទីរសុខាភិបាល ខេត្ត ក្រុង និងដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រង របស់ក្រសួងសុខាភិបាល នូវសាលាមធ្យមសិក្សា សុខាភិបាលភូមិភាគទាំងបួន ដូចខាងក្រោម :

- សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ បាត់ដំបង
- សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ កំពង់ចាម
- សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ កំពត

- សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ ស្ទឹងត្រែង ។

**មាត្រា២.-**

សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ ទាំងបួនខាងលើ មានបេសកកម្មបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកថែទាំវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រទាំងមូលដ្ឋាន ក្រោយមូលដ្ឋាន និងបន្ត ចាប់តាំងពីថ្នាក់ បឋម ដល់ថ្នាក់ មធ្យម ។

**មាត្រា៣.-**

សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ នីមួយៗ ដឹកនាំដោយ នាយកមួយរូប ថ្នាក់ស្មើ ប្រធានមន្ទីរសុខាភិបាល ខេត្ត ក្រុង និង មាននាយករង មួយឬ ច្រើនរូប ថ្នាក់ស្មើអនុប្រធានមន្ទីរសុខាភិបាល ខេត្ត ក្រុង ជាជំនួយការ ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅ របស់សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ នីមួយៗ ត្រូវកំណត់ដោយប្រកាសក្រសួងសុខាភិបាល ។

**មាត្រា៥.-**

បទប្បញ្ញត្តិ ទាំងឡាយណា ដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជា និរាករណ៍ ។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ មានភារៈកិច្ច អនុវត្ត អនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ហុង ស៊ុនហួត**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ...៥៤៣...អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន និង ចលនាសប្បុរសជនចូលរួមកសាងសមិទ្ធផល ដូចជាព្រះវិហារ កុដិ សាលារៀន ស្ពាន ផ្លូវថ្នល់ ស្រះទឹក អណ្តូងទឹក និង ជួយឧបត្ថម្ភដល់ប្រជាពលរដ្ឋក្រីក្រ ដែលជួបប្រទះគ្រោះរាំងស្ងួត និងទឹកជំនន់នា ឆ្នាំ ២០០២ ដូចមានរាយនាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ទល់** | **ឡើប** | ទីប្រឹក្សាយោធាសម្តេចនាយករដ្ឋមន្ត្រី |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ញឹក** | **ឃួន** | នាយរងសេនាធិការចំរុះ |
| ៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **នាង** | **ផាត** | អគ្គនាយក យោធសេវា ក្រសួងការពារជាតិ |
| ៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ស៊ីវឌ្ឍ** | **ឌី** | មេបញ្ជាការរង កងទ័ពជើងគោក |
| ៥-ឯកឧត្តម ឧត្តមសេនីយ៍ទោ | **យូ** | **ស៊ុនឡុង** | ទីប្រឹក្សាសន្តិសុខសម្តេចនាយករដ្ឋមន្ត្រី |
| ៦-ឯកឧត្តម | **សោម** | **ចិន** | សមាជិកសភា មណ្ឌលកំពត |
| ៧-លោកជំទាវ | **ហូ** | **ណាន** | សមាជិកាសភា មណ្ឌលកណ្តាល |
| ៨-លោកជំទាវ | **ឃួន** | **សុដារី** | សមាជិកាសភា មណ្ឌលកណ្តាល |
| ៩-ឯកឧត្តម | **ពៅ** | **សាមី** | អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ១០-ឯកឧត្តម ឧត្តមសេនីយ៍ទោ | **ទ្រាក់** | **ទន្នន្តឌី** | នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី |

១១-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ហ៊ុយ ពិសិដ្ឋ** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី

១២-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ហ៊ឹង ប៊ុនហៀង** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

១៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ចៅ តុល** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

១៤-ឯកឧត្តម **ហ៊ុន ស៊ីថា** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

១៥-ឯកឧត្តម **លឹម លាងសែ** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

១៦-ឯកឧត្តម **គឹម ប៊ុនថាន** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

១៧-ឯកឧត្តម **សេង ឡេង** ជំនួយការសម្តេចនាយករដ្ឋមន្ត្រី

១៨-ឯកឧត្តម **ពិន សុវណ្ណ** ទីប្រឹក្សាសម្តេច **ហេង សំរិន**

១៩-ឯកឧត្តម **ហងៀ សារឿន** អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

២០-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ដាំ វុឌ្ឍី** នាយកទីចាត់ការបុគ្គលិក អគ្គមេបញ្ជាការ

២១-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ឡាញ់ គៅ** មេបញ្ជាការ បញ្ជាការដ្ឋានរថក្រោះ

២២-លោកបណ្ឌិត **សាត សាមី** ប្រធាននាយកដ្ឋានរ៉ែ និង ថាមពល

២៣-ឯកឧត្តម **ហាស់ ទ័រី** អគ្គនាយកក្រុមហ៊ុនកាត់ដេរ ស្ទឹងមានជ័យ

២៤-លោក **មួន លឹមហេង** ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី

២៥-លោក **តូច សុផារ៉ា** អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី

២៦-លោក **ខូយ គឹមតួ** អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី

២៧-លោកស្រី **ទេព សុឌ្ឍី** នាយការិយាល័យផ្គត់ផ្គង់ និងហិរញ្ញកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី

២៨-លោក **ស្វាយ ជូត** នាយរងការិយាល័យផ្គត់ផ្គង់ និងហិរញ្ញកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី

២៩-លោកវរសេនីយ៍ទោ **ខា លីស្រ៊ុន** ជំនួយការឯកឧត្តម **ចៅ តុល**

៣០-លោកវរសេនីយ៍ទោ **សាយ សារុន** មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងតាកែវ

៣១-លោក នាយកក្រុមហ៊ុនកាត់ដេរ **KING FIRST**

៣២-លោក **ឈុន សារ៉ាណេ** នាយកក្រុមហ៊ុន **លី សាងមាន មៀនឃួរ**

៣៣-លោក **ទេង ស្រេង** នាយកក្រុមហ៊ុន វីនិតុន

៣៤-លោក **ថាយ ស៊ុនហ៊ាង** នាយកសាលាមធ្យមសិក្សាកសិកម្មព្រែកលាប

៣៥-លោក **ស៊ី ឃួហ៊ុយ** នាយកក្រុមហ៊ុន ជុងយ៉ា ត្រេឌីង អាហារ័ណ និហារ័ណ

៣៦-លោក **លី តាងស៊ុ** នាយកក្រុមហ៊ុន **MEILOON HONG XING DEVELOPMENT Co,Ltd**

៣៧-លោក **សុខ សីលា** នាយកក្រុមហ៊ុនរុករក និង ស្រាវជ្រាវរ៉ែគ្រប់ប្រភេទ

៣៨-លោក **លី ឃុង** នាយកក្រុមហ៊ុន លី អ៊ួយអាន

៣៩-លោក **ស្នួង សន្តិភាព** ប្រធានអង្គការឧបត្ថម្ភកុមារកំព្រា

៤០-លោក **គង់ សាង** ជំនួយការឯកឧត្តម **ហ៊ឹង ប៊ុនហៀង**

៤១-លោក **ខេន សុភា** ជំនួយការឯកឧត្តម **ហ៊ឹង ប៊ុនហៀង**

៤២-លោក **ហងៀ សារ៉ាវុឌ្ឍ** សប្បុរសជន

៤៣-លោក **ឡូ មិថុនា** សប្បុរសជន

៤៤-លោក ដេវីត ឆាយណាវ៉ា សប្បុរសជន
៤៥-លោក លឹម រចនា សប្បុរសជន
៤៦-លោក សំ ហ៊ុំសេង សប្បុរសជន
៤៧-លោក សេង ឈួន សប្បុរសជន
៤៨-លោក ឃឹម រ័ត្ន សប្បុរសជន
៤៩-លោក ជៀម ឡាក់ សប្បុរសជន
៥០-លោក ជៀប ចំណាន និង លោកស្រី គី យ៉ាណា សប្បុរសជន
៥១-លោកស្រី ភាព ហៀក សប្បុរសជន
៥២-លោក លាង ឃុន សប្បុរសជន
៥៣-លោក ខៀង វណ្ណា សប្បុរសជន
៥៤-លោក ហាក់ ឆៅលាង សប្បុរសជន
៥៥-លោក ធ បូណាវី និងលោកស្រី នុន ស៊ីផារ៉ា សប្បុរសជន
៥៦-លោក ស៊ឹម នី សប្បុរសជន
៥៧-លោក ឃូ ចាន់ធូ សប្បុរសជន
៥៨-លោក គឹម សុភាព សប្បុរសជន
៥៩-លោក ស៊ូ ឡុងវ៉ាន់នី សប្បុរសជន
៦០-លោក ហុង សុខអ៊ាង សប្បុរសជន
៦១-លោក សួស សារិទ្ធ សប្បុរសជន
៦២-លោក អ៊ាប ឈុនស្រ៊ាង និងលោកស្រី គុយ ឆែគាន់ សប្បុរសជន
៦៣-លោក អាំង ស្រ៊ុំ និងលោកស្រី នូ វណ្ណីន សប្បុរសជន

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ៨ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ នាយទាហាន នាយអាវុធហត្ថ និងនាយនគរបាល ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជួយសង្គ្រោះប្រជាពលរដ្ឋ ដែលជួបប្រទះគ្រោះរាំងស្ងួត និងទឹកជំនន់ នាឆ្នាំ ២០០២ ដូចមានរាយនាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ម៉ុន** | **អ៊ុយ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី |
| ២-ឯកឧត្តម | **ធីយ** | **ឿន** | អគ្គលេខាធិការរងរាជរដ្ឋាភិបាល |
| ៣-ឯកឧត្តម | **សេង** | **លឹមនៅ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៤-ឯកឧត្តម | **ម្យ៉ាស់** | **ឈាស់** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៥-ឯកឧត្តម | **នេព** | **ហែន** | អគ្គលេខាធិការរង អាជ្ញាធរ អប្សរា |
| ៦-ឯកឧត្តម | **ឌូ** | **វិចិត្ត** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ៧-ឯកឧត្តម | **ស៊ឹម** | **សួង** | ទីប្រឹក្សាអម ទីស្តីការគណៈរដ្ឋមន្ត្រី ទទួលការងារទេសចរណ៍ |
| ៨-ឯកឧត្តម | **សំ** | **សុខផល** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ |
| ៩-ឯកឧត្តម | **ស្វាយ** | **ស៊ីថា** | អគ្គលេខាធិការក្រុមប្រឹក្សារំសាយទ័ព |
| ១០-ឯកឧត្តម | **ឡេង** | **ប៉េងឡុង** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ |

| | | | |
|---|---|---|---|
| ១១-ឯកឧត្តម | **ស៊ាន** | **វិសុទ្ធ** | ទីប្រឹក្សាឯកឧត្តមទេសរដ្ឋមន្ត្រី **សុខ អាន** |
| ១២-ឯកឧត្តម | **ក្រាញ់** | **តូនី** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ |
| ១៣-ឯកឧត្តម | **នា** | **សុផ្កា** | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |
| ១៤-ឯកឧត្តម | **ស៊ូខ** | **ម៉េងគា** | ទីប្រឹក្សាសម្តេច **ជា ស៊ីម** ទទួលបន្ទុកវិនិយោគអភិវឌ្ឍន៍ និង ទេសចរណ៍ |
| ១៥-ឯកឧត្តម | **សយ** | **សុខា** | អគ្គលេខាធិការក្រុមប្រឹក្សាសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ |
| ១៦-ឯកឧត្តម | **លី** | **គីមសុខ** | នាយកសាលាភូមិន្ទរដ្ឋបាល |
| ១៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **អ៊ុំ** | **បុត្រ** | មេបញ្ជាការរងកងទ័ពជើងគោក |
| ១៨-ឯកឧត្តម | **ង៉ែ** | **ម៉ុនឈឿន** | ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា |
| ១៩-ឯកឧត្តម ឧត្តមសេនីយ៍ទោ | **ឆូ** | **ស៊ុន** | នាយខុទ្ទកាល័យអគ្គមេបញ្ជាការ |
| ២០-ឯកឧត្តម ឧត្តមសេនីយ៍ទោ | **នំយ** | **ម៉ុល** | ប្រធានតុលាការយោធា |
| ២១-ឯកឧត្តម | **ម៉ៃ** | **នរៈសត្យា** | អគ្គនាយកវិទ្យុ និង ទូរទស្សន៍បាយ័ន |
| ២២-លោក ឧត្តមសេនីយ៍ត្រី | **ម៉ៅ** | **សុផាន់** | មេបញ្ជាការកងពលតូចលេខ ៧០ |
| ២៣-លោកឧត្តមសេនីយ៍ត្រី | **ខៀវ** | **សារុន** | មេបញ្ជាការអង្គរក្ស |
| ២៤-លោក ឧត្តមសេនីយ៍ត្រី | **ហេង** | **សារឿន** | មេបញ្ជាការរងអង្គរក្ស |
| ២៥-លោក ឧត្តមសេនីយ៍ត្រី | **សុខ** | **សុខៈ** | មេបញ្ជាការរងអង្គរក្ស |
| ២៦-លោក ឧត្តមសេនីយ៍ត្រី | **អ៊ុំ** | **សារិទ្ធ** | មេបញ្ជាការរងអង្គរក្ស |
| ២៧-លោក ឧត្តមសេនីយ៍ត្រី | **សុខ** | **ចាន់ណា** | មេបញ្ជាការរងអង្គរក្ស |
| ២៨-លោក ឧត្តមសេនីយ៍ត្រី | **សុខ** | **យ៉ាន** | មេបញ្ជាការរងអង្គរក្ស |
| ២៩-លោក ឧត្តមសេនីយ៍ត្រី | **សុខ** | **សុវណ្ណ** | មេបញ្ជាការរងអង្គរក្ស |
| ៣០-លោក ឧត្តមសេនីយ៍ត្រី | **ម៉េង** | **ហាត** | មេបញ្ជាការរងបញ្ជាការដ្ឋានរថក្រោះ |
| ៣១-លោក ឧត្តមសេនីយ៍ត្រី | **នាង** | **អឿង** | មេបញ្ជាការរងយោធភូមិភាគ ១ |
| ៣២-លោក វរសេនីយ៍ឯក | **សោម** | **ជន** | មេបញ្ជាការរងអង្គរក្ស |
| ៣៣-លោក វរសេនីយ៍ឯក | **នេស** | **ចយ** | ស្នងការនគរបាលខេត្តកំពង់ស្ពឺ |
| ៣៤-លោក | **ទ៉ាន់** | **ម៉ុនទេត** | នាយករងសាលាភូមិន្ទរដ្ឋបាល |
| ៣៥-លោក | **ឆៀន** | **ម៉ៅ** | ប្រធាននាយកដ្ឋានឥស្សរិយយស |
| ៣៦-លោក | **ខៀវ** | **ថាវិកា** | ប្រធាននាយកដ្ឋានពត៌មាន |
| ៣៧-លោក | **លឹម** | **សំកុល** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ៣៨-លោក | **កែវ** | **សេង** | ប្រធាននាយកដ្ឋានគ្រឿងយន្តកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៣៩-លោក | **ឌី** | **សុភីន** | ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ៤០-លោក | **ឃួន** | **យ៉ា** | អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ចនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ៤១-លោក | **ជាប** | **ជាវុធ** | អនុប្រធានទី១ នាយកដ្ឋានលទ្ធកម្ម សាធារណៈ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ៤២-លោក | **ម៉ៅ** | **សាមី** | អនុប្រធាននាយកដ្ឋានគ្រឿងយន្តកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៤៣-លោក | **សេង** | **សត្ថា** | ជំនួយការផ្ទាល់ឯកឧត្តមទេសរដ្ឋមន្ត្រី **សុខ អាន** |

| | | |
|---|---|---|
| ៤៤-លោក | **តាន់ សុទិន្យា** | ជំនួយការឯកឧត្តម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម |
| ៤៥-លោក | **និត ថៃរីល** | ខុទ្ទកាល័យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ៤៦-លោក | **កែវ វី** | ជំនួយការឯកឧត្តមអនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ៤៧-លោក | **ឡាំ ហេងហ៊ួត** | ជំនួយការឯកឧត្តមអនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ៤៨-លោក | **អ៊ឹម សុផល** | ជំនួយការឯកឧត្តមអនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ៤៩-លោក | **ពៅ សុភាព** | ប្រធានការិយាល័យ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ៥០-លោក | **ឆាំល់ ចន្ទតារា** | សមាជិកអង្គភាពប្រឆាំងអំពើពុករលួយ |
| ៥១-លោក | **ឈិត ប៊ូរ៉ាវុធ** | មន្ត្រីតុលាការកំពូល |
| ៥២-លោក | **ម៉ែន សំអាត** | ប្រធានការិ.ក្រុមលេខាឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ |
| ៥៣-លោក | **ហ៊ុំ គីមហេង** | ប្រធានសាខាគយខេត្តបន្ទាយមានជ័យ |
| ៥៤-លោក | **ជា វ៉ាន់នី** | ប្រធានសាខាគយខេត្តស្វាយរៀង |
| ៥៥-លោក | **អ៊ុយ សារិន** | ប្រធានការិយាល័យត្រួតពិនិត្យ ទីចាត់ការគយ និង រដ្ឋាករ |
| ៥៦-លោក | **និត ជា** | អនុប្រធានការិយាល័យត្រួតពិនិត្យ ទីចាត់ការគយ និង រដ្ឋាករ |
| ៥៧-លោក | **ធ ប៊ូណារី** | ប្រធានការិយាល័យរដ្ឋាករ ទីចាត់ការគយ និង រដ្ឋាករ |
| ៥៨-លោកវរសេនីយ៍ឯក | **ម៉ិច សុខី** | មេបញ្ជាការរងអង្គរក្ស |
| ៥៩-លោកវរសេនីយ៍ឯក | **នួន ណារិន្ទ** | មេបញ្ជាការរងអង្គរក្ស |
| ៦០-លោកវរសេនីយ៍ឯក | **គង់ វណ្ណា** | មេបញ្ជាការរងអង្គរក្ស |
| ៦១-លោកវរសេនីយ៍ឯក | **អ៊ុំ ម៉ារា** | ជំនួយការឯកឧត្តម **កៀង សាវុធ** |
| ៦២-លោកវរសេនីយ៍ឯក | **ម៉ាង ណាសវ៉ាត** | ជំនួយការឯកឧត្តម **កៀង សាវុធ** |
| ៦៣-លោកវរសេនីយ៍ឯក | **យ៉ាត រិទ្ធ** | នាយសេនាធិការរង កងឯកភាពអង្គរក្ស |
| ៦៤-លោកវរសេនីយឯក | **ហៀង វុទ្ធី** | នាយសេនាធិការរង កងឯកភាពអង្គរក្ស |
| ៦៥-លោកវរសេនីយ៍ឯក | **លីម សុធា** | នាយសេនាធិការរង កងឯកភាពអង្គរក្ស |
| ៦៦-លោកវរសេនីយ៍ឯក | **នុន សុខុន** | នាយសេនាធិការរង កងឯកភាពអង្គរក្ស |
| ៦៧-លោកវរសេនីយ៍ឯក | **នេព សាខន** | នាយកដ្ឋានបច្ចេកទេស ក្រសួងការពារជាតិ |
| ៦៨-លោកវរសេនីយ៍ឯក | **សួន ពិរុណ** | ជំនួយការឯកឧត្តម **ហ៊ីង ប៊ុនហៀង** |
| ៦៩-លោកវរសេនីយឯក | **ឈួន សំអាត** | នាយការិយាល័យរដ្ឋបាល ខុទ្ទកាល័យអគ្គបញ្ជាការ |
| ៧០-លោក | **វ៉ាន់ សុវណ្ណ** | មន្ត្រីពន្ធដារ |
| ៧១-លោក | **ណុប គីមសាន្ត** | មន្ត្រីគយ |
| ៧២-លោក | **ឌុក សុមេធ** | មន្ត្រីគយ |
| ៧៣-លោក | **លាង អ៊ិក** | មន្ត្រីគយ |
| ៧៤-លោក | **កែវ វណ្ណថន** | អនុប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ក្រសួងមហាផ្ទៃ |
| ៧៥-លោក | **អ៊ូ រ៉ាស៊ី** | អគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ក្រសួងយុត្តិធម៌ |
| ៧៦-លោកវរសេនីយ៍ទោ | **ហេង ម៉ិន** | នាយកសាលានគរបាលភូមិភាគ II ក្រសួងមហាផ្ទៃ |
| ៧៧-លោកវរសេនីយ៍ទោ | **កើត សំផន** | នាយកសាលានគរបាលភូមិភាគ I ក្រសួងមហាផ្ទៃ |

| | | |
|---|---|---|
| ៧៨-លោកវរសេនីយ៍ត្រី | **កែវ វណ្ណនា** | នាយករងការិយាល័យគ្រប់គ្រងសាលា ក្រសួងមហាផ្ទៃ |
| ៧៩-លោក | **គង់ ចំរើន** | ជំនួយការអគ្គមេធាវីរាជរដ្ឋាភិបាល |
| ៨០-លោកវរសេនីយ៍ទោ | **ម្ចុង សុធា** | នាយការិយាល័យស៊ើបអង្កេតកន្លែង កើតហេតុ |
| ៨១-លោកវរសេនីយ៍ទោ | **នៅ សារ៉ុន** | នាយទាហានការពារផ្ទាល់ |
| ៨២-លោកវរសេនីយ៍ទោ | **មុិញ ពិសិដ្ឋ** | ជំនួយការឯកឧត្តម **ហ៊ីង ប៊ុនហៀង** |
| ៨៣-លោកវរសេនីយ៍ទោ | **អ៊ុត សោភ័** | ជំនួយការឯកឧត្តម **ហ៊ីង ប៊ុនហៀង** |
| ៣-ឯកឧត្តម សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤-ឯកឧត្តម យូ ហុកគ្រី | ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឯកឧត្តម ព្រុំ សុខា | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |

៦-លោកជំទាវ ស៊ុន សារឿន អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ **សមាជិកា**

៧-ឯកឧត្តម នុត សារាន អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ **សមាជិក**

៨-ឯកឧត្តម សក់ សេដ្ឋា អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ **សមាជិក**

៩-ឯកឧត្តម ទៅ វណ្ណលី អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ **សមាជិកអចិន្ត្រៃយ៍**

**ប្រការ ២** : ក្រុមការងារនេះមានភារកិច្ច :

- សិក្សាប៉ាន់ប្រមាណអំពីតម្រូវការនានា សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ និងសហគមន៍អ្នកផ្តល់ជំនួយនានា ដើម្បីពិភាក្សាសម្រប សម្រួលស្វះស្វែងរកជំនួយបំរើអោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ពិភាក្សាស្វះស្វែងរកការគាំទ្រពីសហគមន៍អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។
- រៀបចំអោយមានកិច្ចប្រជុំជាមួយក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ឬជាមួយសហគមន៍អ្នកផ្តល់ ជំនួយ ឬជាមួយសហគមន៍អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិតាមការចាំបាច់ ។

**ប្រការ ៣** : ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងចំណាយថវិការបស់គណៈរដ្ឋមន្ត្រី ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងឯកឧត្តមដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

*-ទីស្តីការក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
*-តំណាងអង្គការ UNDP ប្រចាំកម្ពុជា*
*- ដូចប្រការ៤*
*- ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ...៥៥...សសរ.....

## សេចក្តីសំរេច

ស្តីពី

**ការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៣ ហៅកាត់ថា "ការិយាល័យសន្តិសុខថ្នាក់កណ្តាល "**

✧

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

<u>ប្រការ ១</u> : ត្រូវបានបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៣ ហៅកាត់ថា "**ការិយាល័យសន្តិសុខថ្នាក់កណ្តាល**" ដែលមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ស ខេង | ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម ទៀ បាញ់ | ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៣-ឯកឧត្តម គាត ឈន់ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤-ឯកឧត្តម យូ ហុកគ្រី | ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ស៊ីរីរ័ត្ន | សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ | សមាជិក |
| ៦-ឯកឧត្តម ឌា ចំរ៉ាន់ | ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារការពារសន្តិសុខសណ្តាប់ធ្នាប់សំរាប់ការបោះឆ្នោត | សមាជិក |
| ៧-ឯកឧត្តម កែ គឹមយ៉ាន | អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ | សមាជិក |

៨-ឯកឧត្តម ហុក ឡុងឌី អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ **សមាជិក**

៩-ឯកឧត្តម សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស **សមាជិក**

**ប្រការ ២** : ការិយាល័យសន្តិសុខថ្នាក់កណ្តាលមានភារកិច្ច ៖

- សហការ សំរបសំរួលជាមួយគណៈកម្មាធិការផ្នែកសន្តិសុខ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- ចាត់តាំងកំលាំងជំនាញមានសមត្ថកិច្ច ចុះសហការអោយបានជិតស្និទ្ធជាមួយយន្តការផ្នែកសន្តិសុខតាមឋានានុក្រម ដើម្បីធានាអោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សា ។
- ផ្សព្វផ្សាយពត៌មាន គោលការណ៍ វិធានការសន្តិសុខ ជូនទៅការិយាល័យសន្តិសុខថ្នាក់ក្រោម ។
- ប្រមូលផ្តុំពត៌មាន ពាក្យបណ្តឹង ទាក់ទិននឹងសន្តិសុខពីការិយាល័យសន្តិសុខខេត្ត ក្រុង ដើម្បីពិនិត្យ ដោះស្រាយ និងបញ្ជាណែនាំ ។
- ប្រមូលផ្តុំចាត់ចែងកំលាំងនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដោយប្រើប្រាស់សំភារៈ ឧបករណ៍ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទរបស់អង្គភាពផ្ទាល់ដែលមានស្រាប់ ដើម្បីរួមចំណែកអនុវត្តកិច្ចប្រតិបត្តិការការពារសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈអោយមានប្រសិទ្ធភាពខ្ពស់ដល់ដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**ប្រការ ៣** : ការិយាល័យសន្តិសុខថ្នាក់កណ្តាលមានសិទ្ធិបង្កើតលេខាធិការដ្ឋាន ដើម្បីជាជំនួយក្នុងការតាមដាន ដឹកនាំ បញ្ជា និងមានសិទ្ធិប្រើប្រាស់ត្រានិងថវិការបស់គណៈរដ្ឋមន្ត្រី ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*__កន្លែងទទួល__ :*

*-ទីស្តីការក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*

*-ដូចប្រការ៤*

*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ៥៥៨ សហវ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០២

## ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការពិនិត្យការដេញថ្លៃ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៩៩ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** បង្កើតគណៈកម្មការមួយដែលមានឈ្មោះថា «គណៈកម្មការពិនិត្យការដេញថ្លៃ» ដើម្បីជ្រើសរើសក្រុមហ៊ុន ឬ អង្គការឱ្យរៀបចំ និងអនុវត្តគំរោងស្វ័យប្រវត្តិកម្មគយ-រដ្ឋាករ ។

**ប្រការ២:** គណៈកម្មការដេញថ្លៃនេះ មានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១.ឯកឧត្តម **ប៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ | ប្រធាន |
| ២.ឯកឧត្តម **សួរ ឡិចធំ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣.លោក **គុណា ញឹម** | នាយករងទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៤.លោក **ម៉ែន សំអាត** | ប្រធានការិយាល័យលេខាធិការ | សមាជិក |

៥. លោក អ៊ុយ សារិន ប្រធានការិយាល័យត្រួតពិនិត្យ សមាជិក

៦. លោក ជា ចារ់ ប្រធានការិយាល័យតំលៃ ស្ថិតិ និងឯកសារ សមាជិក

៧. លោក ប៉ុល គីមសែន ភ្នាក់ងាររតយ-រដ្ឋាករនៃការិយាល័យស្ថិតិ និងពត៌មានវិទ្យា លេខាធិការ

**ប្រការ ៣** : គណៈកម្មការពិនិត្យការដេញថ្លៃមានភារកិច្ចដូចតទៅ÷

១. ពិនិត្យ និងវាយតំលៃតាមលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសក្រុមហ៊ុនឬ អង្គការ ដែលត្រូវរៀបចំ និងអនុវត្តគំរោងស្វ័យប្រវត្តិកម្មគយ-រដ្ឋាករ ។

២. ផ្តល់អនុសាសន៍ និងស្នើសុំសេចក្តីសំរេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើលទ្ធផលនៃការពិនិត្យ និងវាយតំលៃលើឯកសាររបស់ក្រុមហ៊ុនឬអង្គការដាក់ពាក្យចូលដេញថ្លៃ ។

៣. ធ្វើការចរចាជាមួយក្រុមហ៊ុនឬអង្គការដែលត្រូវបានជ្រើសរើស ដើម្បីរៀបចំគំរោង និងកិច្ចសន្យាស្តីពីគំរោងស្វ័យប្រវត្តិកម្មគយ ។

៤. រៀបចំនូវលិខិតបទដ្ឋានផ្សេងៗ ពាក់ពន្ធ័នឹងការអនុវត្តន៍គំរោងស្វ័យប្រវត្តិកម្មគយ ។

៥ . គៀងគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុតាមនិតិវិធី ដើម្បីអនុវត្តគំរោងនេះ ។

**ប្រការ ៤**: គណៈកម្មការពិនិត្យការដេញថ្លៃត្រូវធ្វើការជាមួយអ្នកជំនាញការ IMF អមទីចាត់ការគយ និងរដ្ឋាករ និងមានសិទ្ធិអញ្ជើញមន្ត្រីជំនាញពាក់ពន្ធ័មកប្រជុំពិគ្រោះយោបល់។

**ប្រការ ៥** : គណៈកម្មការពិនិត្យការដេញថ្លៃ បំពេញការងារក្រោមការត្រួតពិនិត្យដោយផ្ទាល់របស់ប្រធានគណៈកម្មការនេះ ។

**ប្រការ ៦**: ប្រកាស ឬសេចក្តីសំរេចណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**: ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ និងសាម៉ីខ្លួន ត្រូវទទួលអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>ចំលងជូន:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរជាតិសវនកម្ម
- ដូចប្រការ៧ «ដើម្បីអនុវត្ត»
- កាលប្បវត្តិ/ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០២-២១៨ (ប.ក)

# ប្រកាស
## ស្តីពី
## ការដាក់អោយអនុវត្តប្លង់គណនី សំរាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

### ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/ ២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១១៩៩ / ១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០២០២/០៣៩ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន
- យោងតាមការសំរេចរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០០២ ។

### សំ រេ ច

**ប្រការ ១.-**

ដាក់ចេញប្លង់គណនី និងកាតព្វកិច្ចបើកចំហពតិមានសំរាប់គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា អោយអនុវត្តដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ ។

**ប្រការ ២.-**

ការអនុវត្តន៍នូវប្លង់គណនីនិងកាតព្វកិច្ចបើកចំហពតិមានត្រូវចាប់ផ្តើមនៅថ្ងៃទី០១ខែមករា ឆ្នាំ២០០៣ ។

**ប្រការ ៣.-**

របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ផ្សេងៗ រួមមានរបាយការណ៍រូបិយវត្ថុដែលត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា សំរាប់ខែមករាឆ្នាំ២០០៣ និងគ្រាបន្តបន្ទាប់ត្រូវបំពេញត្រឹមត្រូវលើមូលដ្ឋានប្លង់គណនី និងកាតព្វកិច្ចបើកចំហពតិមាន ។

**ប្រការ ៤.-**

ធនាគារជាតិនៃកម្ពុជាមានសិទ្ធិបង្កើតបន្ថែម ឬលុបចោលឈ្មោះ និងលេខគណនី តាមការចាំបាច់ ។

**ប្រការ ៥.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ត្រូវអនុវត្តតាមផងដែរនូវស្តង់ដារគណនេយ្យកម្ពុជា ដែលចេញដោយក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ក្នុងករណីដែលកាតព្វកិច្ចគណនេយ្យកំណត់ដោយធនាគារជាតិនៃកម្ពុជាមានភាពខុសគ្នាពីស្តង់ដារគណនេយ្យកម្ពុជា កាតព្វកិច្ចដែលតំរូវដោយធនាគារជាតិនៃកម្ពុជាត្រូវមានប្រសិទ្ធភាពអនុវត្ត ។

**ប្រការ ៦.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០២

**ទេសាភិបាល**

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**KINGDOM OF CAMBODIA**
**NATION RELIGION KING**

**NATIONAL BANK OF CAMBODIA**

Number B7.02.218 Pror. Kor

# Prakas
## On
## Adoption and Implementation of Chart of Accounts
## For
## Banking and Financial Institutions

### The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996 promulgating the Law on the Organization and Functioning of the National Bank of Cambodia
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions
- With reference to the Royal Decree NS/RKT/0202/039 of February 16, 2002 on the reappointment of His Excellency Chea Chanto as Governor General of the National Bank of Cambodia
- Pursuant to the request of the General Direction
- Pursuant to the agreement of the senior officer meeting of the National Bank of Cambodia on December 23, 2002.

### Decides

**Article 1.**

To adopt Chart of Accounts and Disclosure Requirements for implementation and compliance by all banks and financial institutions licensed by the National Bank of Cambodia (NBC) as per annex attached.

**Article 2.**

Implementation of the Chart of Accounts and Disclosure Requirements must be commenced from January 1, 2003.

**Article 3.**

All financial statements and other reports including monetary reports submitted to the (NBC) for the month of January 2003, and all subsequent periods must be completed based upon the Chart of Accounts and Disclosure Requirements.

**Article 4.**

The NBC reserves the right to add or delete account numbers when it requires.

**Article 5.**

All banks and financial institutions must also implement and comply with new Cambodian Accounting Standards (CASs) as they are issued by the Ministry of Economy and Finance.

In the event the accounting requirements imposed by the NBC are different from the CAS, the requirements of the NBC will prevail and take precedence over the CAS.

**Article 6.**

All provisions contrary to those of the present Prakas are hereby repealed.

**Article 7.**

The General Direction, the General Secretariat, the General Cashier, the General Inspection, all departments of the NBC and all Banking and Financial Institutions under the NBC's supervisory authority shall strictly implement this Prakas.

**Article 8.**

The present Prakas shall have effect from the signing date.

Phnom Penh, 25 December, 2002
Governor

Signed and sealed CHEA CHANTO

cc: - The Members of the Board of Directors
- The parties concerned as stated in Article 7
- File
- CM "for info"
- Administration of CM
"for publication in the National Gazette"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២-២១៩ ប្រ.ក

# ប្រកាស
## ស្តីពី
## ការដាក់អោយអនុវត្តប្លង់គណនី សំរាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

---

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/ ២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១១៩៩ / ១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០២០២/០៣៩ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការតែង តាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន
- យោងតាមសេចក្តីសំរេចរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០២

## សំ រេ ច

**ប្រការ ១.-**

ដាក់ចេញប្លង់គណនីនិងកាតព្វកិច្ចបើកចំហពតិមានសំរាប់គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា អោយអនុវត្តដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ ។

**ប្រការ ២.-**

ការអនុវត្តន៍ប្លង់គណនីនិងកាតព្វកិច្ចបើកចំហពតិមានត្រូវចាប់ផ្តើមនៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៣ ។

**ប្រការ ៣.-**

របាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍ផ្សេងៗ ដែលត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា សំរាប់ខែមករា ឆ្នាំ២០០៣ និងគ្រាបន្តបន្ទាប់ត្រូវបំពេញត្រឹមត្រូវលើមូលដ្ឋានប្លង់គណនីនិង កាតព្វកិច្ចបើកចំហពតិមាន ។

## ប្រការ ៤.-

ធនាគារជាតិនៃកម្ពុជាមានសិទ្ធិបង្កើតបន្ថែម ឬលុបចោលឈ្មោះនិងលេខគណនីតាមការចាំបាច់ ។

## ប្រការ ៥.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ត្រូវអនុវត្តតាមផងដែរនូវស្តង់ដារគណនេយ្យកម្ពុជា ដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ក្នុងករណីដែលកាតព្វកិច្ចគណនេយ្យកំណត់ដោយធនាគារជាតិនៃកម្ពុជា មានភាពខុសគ្នាពីស្តង់ដារគណនេយ្យកម្ពុជា កាតព្វកិច្ចដែលតំរូវដោយធនាគារជាតិនៃកម្ពុជាត្រូវមានប្រសិទ្ធភាពអនុវត្ត ។

## ប្រការ ៦.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

## ប្រការ ៧.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

## ប្រការ ៨.-

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០២

**ទេសាភិបាល**

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION . RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.02...219 Pror Kor

# Prakas
## On
## Adoption and Implementation of Chart of Accounts For Micro-finance Institutions

*The Governor of the National Bank of Cambodia*

- With reference to the Constitution of the Kingdom of Cambodia
- With reference to the Royal Kram NS/RKM/0196/27 of January 26, 1996 promulgating the Law on the Organization and Functioning of the National Bank of Cambodia
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions
- With reference to the Royal Decree NS/RKT/0202/039 of February 16, 2002 on the reappointment of His Excellency Chea Chanto as Governor General of the National Bank of Cambodia
- Pursuant to the request of the General Direction
- Pursuant to the agreement of the senior officer meeting of the National Bank of Cambodia on December 23, 2002.

**Decides**

**Article 1.**

To adopt Chart of Accounts and Disclosure Requirements for implementation and compliance by all Micro-finance institutions licensed by the National Bank of Cambodia as per annex attached.

**Article 2.**

Implementation of the Chart of Accounts and Disclosure Requirements must be commenced from January 1, 2003.

**Article 3.**

All financial statements and other reports including monetary reports submitted to the National Bank of Cambodia for the month of January 2003, and all subsequent periods must be completed based upon the Chart of Accounts and Disclosure Requirements.

**Article 4.**

The National Bank of Cambodia reserves the right to add or delete account numbers when it is required.

**Article 5.**

Micro-finance institutions must also implement and comply with Cambodian Accounting Standards as they are issued by the Ministry of Economy and Finance.

In the event the accounting requirements imposed by the National Bank of Cambodia are different from Cambodian Accounting Standards, the requirements of the National Bank of Cambodia will prevail and take precedence over Cambodian Accounting Standards.

**Article 6.**

All provisions contrary to this Prakas are hereby repealed.

**Article 7.**

The General Direction, the General Secretariat, the General Cashier, the General Inspection, all departments of the National Bank of Cambodia and all Micro-finance Institutions under of the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 8.**

This Prakas shall have effect from the signing date.

Phnom Penh ...25/12......, 2002
Governor

Signed and sealed CHEA CHANTO

cc: - The Members of the Board of Directors
- The parties concerned as stated in Article 7
- File
- CM "for info"
- Administration of CM
"for publication in the National Gazette"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០២.២២០ ប្រ.ក.

# ប្រកាស
# ស្តីពី
# ប្រតិបត្តិការលើមូលបត្ររបស់ធនាគារ ដែលមានអាជ្ញាប័ណ្ណ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

~~~~~~~~~~

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃ ធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៣៩ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាជាថ្មីម្តងទៀត
- តាមសំណើរបស់អគ្គនាយកដ្ឋាន
- យោងតាមការឯកភាពរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០០២

## ស ំ រេ ច

### ប្រការ ១:

ធនាគារជាតិនៃកម្ពុជាគាំទ្រនិងបង្កលក្ខណៈអំណោយផលដល់ការរីកលូតលាស់និងកិច្ចអភិវឌ្ឍន៍នៃទីផ្សារមូលប័ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលការណ៍សុវត្ថិភាព ភាពរឹងមាំ និងប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងសំរបសំរួលនីតិវិធីគណនេយ្យ និងប្រតិបត្តិការរបស់ខ្លួនក្នុងគោលបំណងសំរួលការផ្តល់ឥណទាន និងការជួញដូរមូលប័ត្រជាអន្តរធនាគារ ។ លើសពីនេះទៀត ធនាគារជាតិនៃ
~~~~~~~~~~

កម្ពុជានឹងអនុវត្តនូវស្តង់ដារពិសេសសំរាប់ធ្វើការត្រួតពិនិត្យធនាគារទាំងឡាយដែលដើរតួជាជើងសារកាវី ឬជាប្រតិបត្តិករមូលប័ត្រ ។

## ប្រការ ២:

ធនាគារត្រូវបានចាត់ទុកថាជាប្រតិបត្តិករជើងសារកាវីឬជាប្រតិបត្តិករមូលប័ត្រ បើធនាគារនោះផ្តល់ការធានាឬជួញដូរ ឬធ្វើប្រព្រឹត្តិកម្មមូលប័ត្រ ។ ប្រសិនបើការទិញនិងលក់មូលប័ត្ររយៈពេលខ្លី តាមរូបភាពដដែល១បង្ហាញឱ្យប្រតិបត្តិករមូលប័ត្រឬវិនិយោគិនដទៃទៀតយល់ឃើញថា ធនាគារធ្វើប្រតិបត្តិការលើមូលប័ត្រ ធនាគារនោះត្រូវបានចាត់ទុកថាធ្វើសកម្មភាពជួញដូរមូលប័ត្រ ដោយពុំគិតដល់ផ្នែកណាមួយនៃធនាគារជាអ្នកចាត់ចែងដំណើរប្រតិបត្តិការទាំងនោះឡើយ ។

## ប្រការ ៣:

ការសំរបសំរួលនីតិវិធីប្រតិបត្តិការនិងគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជា រួមមានការអនុញ្ញាតឱ្យធនាគារ ផ្ទេរមូលនិធិពីគណនីចរន្តរបស់ខ្លួនទៅកាន់គណនីចរន្តរបស់ធនាគារដទៃនៅធនាគារជាតិនៃកម្ពុជា តាមវិធីប្រើបញ្ជាទូទាត់តាមទូរស័ព្ទជាលើកដំបូងទៅធនាគារជាតិនៃកម្ពុជា ដោយមានការសួរបញ្ជាក់តបវិញ ។ ដើម្បីអនុវត្តវិធីនេះ ធនាគារបញ្ជាផ្ទេរប្រាក់ និងធនាគារទទួលប្រាក់ ចាំបាច់ត្រូវធ្វើកិច្ចព្រមព្រៀងគោល ដែលត្រូវផ្ញើជូនមកធនាគារជាតិនៃកម្ពុជាជាមុន ។ កិច្ចព្រមព្រៀងនេះត្រូវចែងអំពីប្រការទាំងឡាយបង្ហាញពីការស្រុះស្រួលគ្នាធ្វើប្រតិបត្តិការបែបនេះ និងមានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាលរបស់សាមីធនាគាររៀង១ខ្លួនផងដែរ ។

លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជានឹងបង្កើតប្រព័ន្ធចុះបញ្ជីសំរាប់មូលប័ត្ររបស់រដ្ឋាភិបាលនៅពេលណាដែលមូលប័ត្រនេះត្រូវបានចេញផ្សាយ ។ កិច្ចព្រមព្រៀងផ្ទេរតាមទូរស័ព្ទដូចគ្នាខាងលើសំរាប់ការជួញដូរមូលប័ត្ររបស់រដ្ឋាភិបាលក្នុងចំណោមធនាគារ នឹងត្រូវបង្កើតឡើងនៅពេលនោះ ។

## ប្រការ ៤:

ធនាគារជាតិនៃកម្ពុជានឹងធ្វើការត្រួតពិនិត្យលើសកម្មភាពរបស់ធនាគារ ដែលធ្វើសកម្មភាពជួញដូរមូលប័ត្រ ។ នីតិវិធីនៃការត្រួតពិនិត្យរួមមានការត្រួតពិនិត្យមើលក្រុមប្រឹក្សាភិបាលនិងការគ្រប់គ្រង ការត្រួតពិនិត្យលើគោលនយោបាយនិងកំរិតហានិភ័យ ការថែរក្សាឯកសារកត់ត្រានិងភាពត្រឹមត្រូវនៃប្រតិបត្តិការ ការអនុវត្តការជួញដូរនិងការបែងចែកភារកិច្ច ការងារបណ្តុះបណ្តាលនិងកម្មវិធីផ្តល់កំរៃដល់ប្រតិបត្តិករនិងបុគ្គលិក ការកាន់កាប់មូលប័ត្រនិងការកត់ត្រាការជួញដូរ និងទិដ្ឋភាពដទៃទៀតនៃប្រតិបត្តិការទាំងឡាយដែលពាក់ព័ន្ធ ។ ការត្រួតពិនិត្យបែបនេះអាចជាផ្នែកមួយនៃការត្រួតពិនិត្យ ជារួមទៅលើធនាគារ ឬអាចមានលក្ខណៈដោយឡែកពីការត្រួតពិនិត្យដទៃទៀត ។

## ប្រការ ៥:

រាល់របាយការណ៍ត្រួតពិនិត្យទាំងអស់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា គឺជាកម្មសិទ្ធិផ្តាច់មុខរបស់ធនាគារជាតិនៃកម្ពុជា ហើយមិនអាចថតចំលង ឬបញ្ជូនដោយគ្មានការឯកភាពពីធនាគារជាតិនៃកម្ពុជាឡើយលើកលែងតែក្នុងករណីដែលច្បាប់អនុញ្ញាត ។

## ប្រការ ៦:

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

## ប្រការ ៧:

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និង គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលនៃធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

## ប្រការ ៨:

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚

រាជធានីភ្នំពេញ, ថ្ងៃទី២៥ខែ ធ្នូ ឆ្នាំ ២០០២

**ទេសាភិបាល**

ជា-ចាន់តូ

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៧ ដើម្បីអនុវត្ត
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA

NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.02.220 Pror Kor

# Prakas

# on

# Broker Dealer Operation of Banks Licensed in Cambodia

-----------

The Governor of National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996 promulgating the Law on the Organization and Functioning of the National Bank of Cambodia
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions
- With reference to the Royal Decree NS/RKT/0202/039 of February 16, 2002 on the reappointment of His Excellency Chea Chanto as Governor of the National Bank of Cambodia
- Pursuant to the request of Directorate.
- Pursuant to the National Bank of Cambodia's Management approval meeting on December 23, 2002.

## DECIDES

**Article 1:**

The National Bank of Cambodia supports and creates conditions favourable to the growth and development of the securities market in Cambodia, consistent with the principles of safety, soundness and efficiency of the financial system. To further that end, the NBC will coordinate its accounting and operational procedures so as to facilitate interbank lending and trading of securities. Further, the National Bank of Cambodia shall implement specialized standards for the examination of banks acting as broker – dealers in securities.

**Article 2:**

A bank is considered to be operating as a securities broker-dealer if it underwrites, trades, or deals in securities. If a repetitive pattern of short-term purchases and sales of securities demonstrates that the bank portrays itself to other dealers or investors as a securities dealer, the bank is trading in securities, regardless of what section of the bank processes the transactions.

**Article 3:**

The coordination of operational and accounting procedure of the National Bank of Cambodia includes the permissibility for designated banks to transfer funds from their current account to current accounts of other banks at the National Bank of Cambodia by initial telephone instruction to the National Bank of Cambodia, followed by call-back reconfirmation. In order to implement this method, transferring banks and their recipient banks must have established a Master Agreement, which shall be previously sent to the National Bank of Cambodia. The Agreement must delineate their desire to enter into such transactions, and the authorizations of respective individual banks.

Additionally, the National Bank of Cambodia will establish a book entry system for government securities when such securities are issued. Similar telephone-call transfer protocols for government securities trading among designated banks would then be established.

**Article 4:**

The National Bank of Cambodia will examine broker–dealer activities in banks practicing securities trading. Examination procedures include board and management oversight, policies and risk limits, record keeping and operational accuracy, trading practices and separation of duties, training and compensation schemes of operators and staff, securities holdings and trading records and any other aspect of operations deemed relevant. Such examination findings may be part of a bank general examination or may be independent of other examination reports.

**Article 5:**

All examination reports issued by the National Bank of Cambodia are the sole property of the National Bank of Cambodia and may not be duplicated or otherwise transmitted without the written consent of the National Bank of Cambodia, unless as provided under law.

**Article 6:**

All provisions contrary to this Prakas are hereby repealed.

**Article 7:**

The General Direction, the General Secretariat, the General Cashier, the General Inspection, all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the NBC's supervisory authority shall implement this Prakas.

**Article 8:**

This Prakas shall have effect from the signing date

Phnom Penh, 25 December, 2002

**The Governor**

Signed and Sealed

**CHEA CHANTO**

cc:
- The parties concerned as stated in Article 7
- File
- Administration
- The Members of the Board of Directors
- CM "for information"
- Administration Department of CM "for publication in the National Gazette"

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ២៧២៨ ប្រ.ក

# ប្រកាស
## ស្តីពីនីតិវិធីនិងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅ ក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរ ឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ សំរាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត

## សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃ ទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦. ០៨ ចុះថ្ងៃ ទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម ០៩០២/០១៧ ចុះថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃ ទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ .បក ចុះថ្ងៃ ទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ស្តីពីសៀវភៅស្នាក់នៅ

-បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៧ ស្តីពីសៀវភៅគ្រួសារ

-យោងលិខិត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៤ .១១/០២ គ.ជ.ប ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០២

-យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សំរេច

ប្រការ ១ .- ប្រកាសនេះមានគោលដៅកំណត់នីតិវិធី និង បែបបទសំរាប់អាជ្ញាធរ ឃុំ សង្កាត់ ចេញលិខិតបញ្ជាក់ទីលំនៅជូនប្រជាពលរដ្ឋខ្មែរដែលមានទីលំនៅក្នុង ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា សំរាប់ប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោតតាមការកំណត់នៃច្បាប់បោះឆ្នោត ។

ប្រការ ២.- ទីលំនៅរបស់ជនណាម្នាក់ ក្នុង ឃុំ សង្កាត់ ណាមួយ គឺជាទីកន្លែងដែលជននោះធ្លាប់រស់នៅជាធម្មតា ហើយតែងតែវិលត្រឡប់មកទីកន្លែងនោះវិញបន្ទាប់ពីអវត្តមានមួយរយៈមក ។

ប្រការ ៣.- មេឃុំ ចៅសង្កាត់ គឺជាតំណាងអោយអាជ្ញាធរ ឃុំ សង្កាត់ ក្នុងការអនុវត្តនីតិវិធី និង បែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅតាមប្រការទាំងឡាយ នៃប្រកាសនេះ ។

ក្នុងករណីមេឃុំ ចៅសង្កាត់អវត្តមាន ត្រូវប្រគល់សិទ្ធិជូនជំទប់ឬចៅសង្កាត់រងតាមឋានានុក្រមអោយបំពេញការងារនេះជំនួស ។

ក្នុងករណីដែលមានប្រជាពលរដ្ឋច្រើនមកបំពេញបែបបទសុំលិខិតបញ្ជាក់ទីលំនៅ មេឃុំ ចៅសង្កាត់ អាចចាត់អោយជំទប់ ឬចៅសង្កាត់រងជួយខ្លួន ឬបំពេញការងារនេះក្នុងនាមខ្លួនតាមការចាំបាច់ ។

ប្រការ ៤.- ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបោះឆ្នោត និង មានទីលំនៅពិតប្រាកដក្នុង ឃុំ សង្កាត់ ប៉ុន្តែមិនទាន់បានចុះបញ្ជី ក១ ឬ បញ្ជី ក៣ ឬសៀវភៅស្នាក់នៅ ក២ ឬសៀវភៅគ្រួសារ ក៤ ក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងស្នាក់នៅ មានសិទ្ធិស្នើសុំអោយអាជ្ញាធរឃុំ សង្កាត់ចេញលិខិតបញ្ជាក់ទីលំនៅសំរាប់ប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត ។

ប្រការ ៥.- ដើម្បីទទួលបានលិខិតបញ្ជាក់ទីលំនៅ ពីអាជ្ញាធរ ឃុំ សង្កាត់ សាមី ប្រជាពលរដ្ឋខ្មែរដូចចែងក្នុងប្រការ៤ ត្រូវទៅបង្ហាញខ្លួនដោយខ្លួនឯងផ្ទាល់នៅចំពោះមុខ មេឃុំ ចៅសង្កាត់ នៃឃុំ សង្កាត់ដែលខ្លួនកំពុងស្នាក់នៅ ។

ប្រការ ៦.- ក្នុងពេលទៅបង្ហាញខ្លួន ប្រជាពលរដ្ឋត្រូវនាំទៅជាមួយខ្លួននូវសាក្សីដែលមានសិទ្ធិបោះឆ្នោត១រូបដែលរស់នៅក្នុង ឃុំ សង្កាត់ ជាមួយ និងឯកសារសំគាល់ខ្លួន ឬឯកសារផ្សេងទៀត ទោះជាឯកសារនោះមានចុះទីលំនៅនៅ ឃុំ សង្កាត់ផ្សេង ឬ មិនបានចុះទីលំនៅក៏ដោយ ។

ឯកសារសំគាល់ខ្លួន ឬឯកសារផ្សេងទៀត ខាងលើនេះ អាចជាអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត ប័ណ្ណសំគាល់ខ្លួនសិស្សនិស្សិត ឬនិយោជិត កម្មករ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ...។

ប្រការ ៧.- ប្រជាពលរដ្ឋដែលពុំមានឯកសារអ្វីសោះសំរាប់បញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន ក្នុងពេលបង្ហាញខ្លួន ប្រជាពលរដ្ឋទាំងនោះត្រូវនាំទៅជាមួយនូវសាក្សីដែលមានសិទ្ធិបោះឆ្នោត ២ រូប ដែលរស់នៅលំនៅដ្ឋានជាមួយ ឬមានលំនៅដ្ឋានក្បែរលំនៅដ្ឋានរបស់សាមីខ្លួនអ្នកសុំបញ្ជាក់ទីលំនៅ ។

ប្រការ ៨.- ក្នុងពេលបង្ហាញខ្លួនចំពោះមុខអាជ្ញាធរ ឃុំ សង្កាត់ សាក្សីដែលបានចែងក្នុងប្រការ៦ និងប្រការ ៧

នៃប្រកាសនេះ ត្រូវនាំយកទៅជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណ ដែលមានចុះអំពីទីលំនៅរបស់សាក្សីទាំងនោះ ។

ប្រការ ៩.- កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ និង នគរបាលជាតិ ដែលរស់នៅប្រមូលផ្តុំក្នុងបន្ទាយ មិនមែនជាគេហដ្ឋានផ្ទាល់របស់ខ្លួន អាចចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បាន ។ ក្នុងករណីបន្ទាយដែលសាមីខ្លួនរស់នៅប្រមូលផ្តុំនេះនៅឆ្ងាយពីលំនៅដ្ឋានរបស់ខ្លួនរស់នៅជាប់លាប់ ដែលមិនអាចអោយសាមីខ្លួនចុះឈ្មោះបោះឆ្នោតជាមួយគ្រួសាររបស់ខ្លួន នៅឃុំ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់ហើយសាមីខ្លួន មានបំណងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលបន្ទាយខ្លួនតាំងនៅ សាមីខ្លួនត្រូវស្នើសុំអោយប្រធានអង្គភាពធ្វើលិខិតបញ្ជាក់ ដោយបញ្ជាក់អោយបានច្បាស់អំពី នាមត្រកូល នាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត និងទីលំនៅផ្ទាល់របស់សាមីខ្លួន (លំនៅដ្ឋានមុនពេលមកនៅក្នុងបន្ទាយ) រួចហើយនាំយកលិខិតបញ្ជាក់នេះ និង ប័ណ្ណសំគាល់ខ្លួនជាកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ នគរបាលជាតិ មកបង្ហាញខ្លួនផ្ទាល់ ចំពោះមុខអាជ្ញាធរឃុំ សង្កាត់ ដែលបន្ទាយអង្គភាពខ្លួនតាំងនៅ ដើម្បីចេញលិខិតបញ្ជាក់ទីលំនៅជូន ។

ប្រការ ១០.- ព្រះសង្ឃ ឬបព្វជិតនៃសាសនានានា ដែលស្នាក់នៅប្រមូលផ្តុំក្នុងវត្ត ឬអារាម ឬវិហារសាសនានានា ដែលមិនមែនជាគេហដ្ឋានផ្ទាល់ ហើយដែលមានបំណងចុះឈ្មោះបោះឆ្នោតក្នុង ឃុំ សង្កាត់ ដែលវត្ត ឬអារាម ឬវិហារសាសនាទាំងនោះតាំងនៅ ព្រះសង្ឃឬបព្វជិតនៃសាសនាទាំងនោះត្រូវស្នើសុំអោយចៅអធិការវត្ត ឬ មេអារាម ឬ មេវិហារសាសនា ដែលមានការទទួលស្គាល់ត្រឹមត្រូវធ្វើលិខិតបញ្ជាក់ ដោយបញ្ជាក់អោយច្បាស់អំពី នាមត្រកូល នាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត និងទីលំនៅផ្ទាល់មុនពេលគង់ឬស្នាក់នៅក្នុងវត្ត ឬអារាម ឬវិហារសាសនាទាំងនោះ រួចហើយនាំយកលិខិតបញ្ជាក់នោះរួមនឹងឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតបើមាន មកបង្ហាញ ផ្ទាល់ខ្លួនចំពោះមុខអាជ្ញាធរ ឃុំ សង្កាត់ ដែលវត្ត ឬអារាម ឬវិហារសាសនាទាំងនោះតាំងនៅដើម្បីចេញលិខិតបញ្ជាក់ទីលំនៅជូន ។

ប្រការ ១១.- មេឃុំ ចៅសង្កាត់ ឬអ្នកដែលបានទទួលការផ្ទេរសិទ្ធិ ក្នុងករណីពិនិត្យឃើញប្រជាពលរដ្ឋបានបំពេញតាមនីតិវិធី និងបែបបទស្របតាមប្រកាសនេះហើយ ត្រូវចេញលិខិតបញ្ជាក់ទីលំនៅជូនប្រជាពលរដ្ឋនោះភ្លាម តាមគំរូដែលភ្ជាប់ជាមួយប្រកាសនេះ ដោយមិនត្រូវពន្យារពេលវេលាឡើយ ។

ប្រការ ១២ .- ការចេញលិខិតបញ្ជាក់ទីលំនៅខាងលើនេះ ត្រូវផ្តល់ជូនប្រជាពលរដ្ឋដោយមិនតម្រូវអោយប្រជាពលរដ្ឋបង់ថ្លៃអ្វីទាំងអស់ ។

ប្រការ ១៣.- ប្រជាពលរដ្ឋខ្មែរ ដែលបានចែងក្នុងប្រការ ៤ នៃប្រកាសនេះ មានសិទ្ធិសុំលិខិតបញ្ជាក់ទីលំនៅបានតែមួយ និងក្នុង ឃុំ សង្កាត់តែមួយប៉ុណ្ណោះក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ១៤.- លិខិតបញ្ជាក់ទីលំនៅតាមស្មារតីនៃប្រកាសនេះ មិនត្រូវផ្តល់ជូនជនបរទេសឡើយ ។

ប្រការ ១៥.- ជនណាដែលប្រព្រឹត្តល្មើសនឹងប្រការទាំងឡាយនៃប្រកាសនេះ នឹងត្រូវផ្តន្ទាទោសតាមច្បាប់ ។

ប្រការ ១៦.- ប្រកាសទាំងឡាយណាដែលផ្ទុយពីប្រកាសនេះចាត់ទុកជានិរាករណ៍ ។

ប្រការ ១៧.- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត ក្រុង អភិបាលស្រុក ខណ្ឌ អាជ្ញាធរឃុំ សង្កាត់ មានភារៈអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០២*

**សហរដ្ឋមន្ត្រី**

ស ខេង យូ ហុកគ្រី

**កន្លែងទទួល :**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចប្រការ ១៧*
*-ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង ................
ស្រុក ខណ្ឌ ................
សាលាឃុំ សង្កាត់

## គំរូ
## លិខិតបញ្ជាក់ទីលំនៅ

-យោងប្រកាសក្រសួងមហាផ្ទៃ លេខ ............................ចុះថ្ងៃទី..........................................

យើងមេឃុំ, ចៅសង្កាត់.....................................................................................................

ស្ថិតក្នុងស្រុក , ខណ្ឌ .............................................. ខេត្ត ក្រុង.................................................

សូមបញ្ជាក់ថា

-ឈ្មោះ............................................ ភេទ..........................................................

-កើតនៅ ថ្ងៃទី....................ខែ ................... ឆ្នាំ ...............................................

ពិតជាមានទីលំនៅផ្ទះលេខ ........................ផ្លូវលេខ....................................ភូមិ.............................

ឃុំ សង្កាត់...................................ស្រុក ខណ្ឌ..................................ខេត្ត ក្រុង..........................

ប្រាកដមែន ។

លិខិតបញ្ជាក់នេះធ្វើឡើងដោយផ្អែកលើឯកសារបញ្ជាក់អត្តសញ្ញាណ..........................................

ឬ/និងការឆ្លើយបញ្ជាក់របស់សាមីខ្លួន សាក្សី :

១.ឈ្មោះ.............................អាយុ ............ឆ្នាំ ភេទ.......... ទីលំនៅ...................................

..........................................................................................................................................

២.ឈ្មោះ.............................អាយុ ............ឆ្នាំ ភេទ.......... ទីលំនៅ...................................

..........................................................................................................................................

ពិតជាត្រឹមត្រូវ និងទទួលខុសត្រូវចំពោះមុខច្បាប់ ។

លិខិតបញ្ជាក់ទីលំនៅនេះ យើងចេញជូនសាមីខ្លួនដើម្បីធ្វើជាឯកសារ សុំចុះឈ្មោះបោះឆ្នោតតាមការកំណត់នៃច្បាប់បោះឆ្នោត ។

ធ្វើនៅ.........................................ថ្ងៃទី ............ខែ................ឆ្នាំ...............

មេឃុំ ចៅសង្កាត់

ស្នាមមេដៃ

សាមីខ្លួន សាក្សី សាក្សី